00640652

E27

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ២៧ មករា ២០១១

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 01 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ **សាធារណៈ**:

ចំណាត់ថ្នាក់ឯកសារដោយ អជសដ សាធារណៈ / Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំបន្ថែមចំនួនទំព័រ និងពន្យារពេលសម្រាប់ករណីអញ្ញត្រកម្មបឋម

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

**ជំនួយការ៖**

លោកស្រី សេង សុជាតា

លោក Frédéric HIVON

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

លោក Archibald CELEYRON

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

E27

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## ១. សេចក្តីផ្តើម

១. មាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តពាក់ព័ន្ធទៅនឹងការដាក់ឯកសារទៅ អ.វ.ត.ក. (“សេចក្តីណែនាំអនុវត្ត”) បានចែងថា “ឯកសារដែលបានដាក់ទៅកាន់ (...) អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក. មិនអាចលើសពី១៥ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬមិនអាចលើសពី៣០ ទំព័រ ជាភាសាខ្មែរ លើកលែងតែមានបទបញ្ញត្តិផ្ទុយ ដែលចែងដោយវិធានផ្ទៃក្នុង ដោយសេចក្តីណែនាំអនុវត្ត ឬ សេចក្តីសម្រេចរបស់ អ.វ.ត.ក”។

២. យោងលើមាត្រា ៧ នៃសេចក្តីណែនាំអនុវត្ត “ឯកសារត្រូវបានដាក់ជាភាសាខ្មែរ ជាភាសាអង់គ្លេស និង/ឬ ជាភាសាបារាំង”។

៣. វិធាន ៨៩ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. (“វិធានផ្ទៃក្នុង”) បានទុករយៈពេល ៣០ ថ្ងៃដល់ក្រុមមេធាវីការពារដើម្បីលើកឡើងអំពីករណីអញ្ញត្រកម្មបឋម គិតចាប់តាំងពីពេលដែលដីកាបញ្ជូនរឿងទៅជម្រះបានចូលជាធរមាន។ ករណីអញ្ញត្រកម្មបឋម “ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ការរំលត់បណ្តឹងអាជ្ញា មោឃភាពនៃនីតិវិធីដែលដំណើរការក្រោយការចេញដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។”

## ២. ភាពដែលអាចទទួលយកបាន

៤. យោងលើមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្ត “អង្គជំនុំជម្រះដែលមានយុត្តាធិការ អាចបន្ថែមចំនួនទំព័រអតិបរមា ក្នុងកាលៈទេសៈពិសេស តាមសំណើសុំរបស់បុគ្គលដែលពាក់ព័ន្ធ”។

៥. វិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើការពន្យាររយៈពេលដូចដែលបានកំណត់ តាមសំណើសុំរបស់ភាគី។

## ៣. អំណះអំណាង

៦. លោក ខៀវ សំផន មានសិទ្ធិទទួលបាន "ពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដែលចាំបាច់ដល់ការត្រៀមរៀបចំការពារខ្លួនចំពោះមុខតុលាការ [1]"។

៧. លោក ខៀវ សំផន ទើបតែបានដឹងអំពីភស្តុតាងដាក់បន្ទុកស្តាពរប្រឆាំងនឹងរូបគាត់ បន្ទាប់ពីមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានចេញកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១[2] ។

៨. ករណីអញ្ញត្រកម្មបឋមបានលើកឡើងនូវបញ្ហាគតិយុត្តិដែលមានលក្ខណៈស្មុគ្រស្មាញ។ សិទ្ធិក្នុងការលើកឡើងនូវករណីអញ្ញត្រកម្មបឋម គឺជាសិទ្ធិជាសារវន្តរបស់ជនត្រូវចោទ ក្នុងខណៈដែលអញ្ញត្រកម្មបឋមទាំងនោះ អាចអនុញ្ញាតឱ្យគេកំណត់បាននូវយុត្តាធិការនៃអង្គជំនុំជម្រះលើករណីរបស់ជនត្រូវចោទនោះ។ ជាមួយគ្នានេះដែរ អញ្ញត្រកម្មបឋមគឺជាវេទិកាចុងក្រោយមួយដែលអនុញ្ញាតឱ្យលោក ខៀវ សំផន អាចធ្វើការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ព្រមទាំងស្នើសុំឱ្យមានការរំលត់បណ្តឹងអាជ្ញា ក៏ដូចជាមោឃភាពនៃកិច្ចនីតិវិធីដែលត្រូវបានបញ្ចប់ ក្រោយពីមានដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

៩. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទចោទចំនួនប្រាំបួន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទចោទចំនួនប្រាំ នៃការរំលោភធ្ងន់ធ្ងរ

---

[1] មាត្រា១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការចោទប្រកាន់ស្របតាមច្បាប់របស់កម្ពុជា ទៅលើជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ។ មាត្រា៣៥ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីចោទប្រកាន់លើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ។ មាត្រា១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ។

[2] សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការលេខ* D427/4/14

លើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងបទល្មើសចំនួនបីទៀតលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[3]។ អញ្ញត្រកម្មបឋមអាចជាការជំទាស់ទៅនឹងយុត្តាធិការនៃអង្គជំនុំជម្រះពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងមូលទៅលើរូបលោក។ លោក ខៀវ សំផន បានលើកឡើងថា ការកម្រិតចំនួន១៥ ទំព័រ មិនគ្រប់គ្រាន់ឡើយក្នុងការលើកឡើងអំពីករណីអញ្ញត្រកម្មបឋមទាំងមូលនោះ។ ជាឧទាហរណ៍ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ មានចំនួនរហូតដល់១៤៤ ទំព័រ ដែលទន្ទឹមគ្នានេះ ចំនួនទំព័រដែលកំណត់ ដោយវិធានមានត្រឹមតែ ៣០ ទំព័រ ប៉ុណ្ណោះ[4]។ លោក ខៀវ សំផន មិនអាចធ្វើការប៉ាន់ស្មានភ្លាមៗអំពីចំនួនទំព័រនៃបណ្តឹងឡើយ ហើយលោកបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងកុំឲ្យធ្វើការដាក់កម្រិតទៅលើរូបលោក ទាក់ទងនឹងចំនួនទំព័រនៃបណ្តឹង ហើយទោះជាយ៉ាងណា បណ្តឹងមិនអាចមានចំនួនលើសពី១០០ ទំព័រ ឡើយ។

១០. ផ្អែកលើចំនួនទំព័រនៃបណ្តឹង រយៈពេល៣០ថ្ងៃ ដែលអនុញ្ញាតដោយវិធានផ្ទៃក្នុង មិនគ្រប់គ្រាន់សម្រាប់ការដាក់បណ្តឹងលើករណីអញ្ញត្រកម្មបឋមជាពីរភាសា បារាំង និងខ្មែរ ក្នុងពេលដំណាលគ្នាបានឡើយ។ ជាក់ស្តែង រយៈពេលនេះត្រូវបានបង្រួញ ដោយហេតុគេត្រូវរង់ចាំការបកប្រែជាមុនសិន[5]។ មេធាវីការពារក្តីលោក ខៀវ សំផន ត្រូវការដាច់ខាតនូវរយៈពេលបន្ថែមទៀត សម្រាប់ដាក់បណ្តឹងពាក់ព័ន្ធនឹងអញ្ញត្រកម្មបឋមជាភាសាខ្មែរ។ ដូច្នេះ លោក ខៀវ សំផន បានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីអនុញ្ញាតដល់រូបលោក ក្នុងការដាក់បណ្តឹងជាភាសាបារាំងតែមួយគត់ ក្នុងរយៈពេល៣០

---

[3] ដីកាដំណោះស្រាយចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ *ឯកសារតុលាការលេខ* D427 កថាខណ្ឌ១៦១៣ ។

[4] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។ *ឯកសារតុលាការលេខ* D427/1/6 ។ ភាពដែលអាចទទួលបានរបស់បណ្តឹងនេះមិនបានចោទជាបញ្ហាឡើយ៖ សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ទំព័រទី ៤ ឯកសារតុលាការលេខ D427/1/26។

[5] ជាឧទាហរណ៍ គេត្រូវការរយៈពេល១សប្តាហ៍ដើម្បីធ្វើការបកប្រែជាភាសាខ្មែរ នូវសំណើសុំដោះលែងឲ្យមានសេរីភាព យោងលើវិធាន៨២ (៣) នៃវិធានផ្ទៃក្នុងដែលបានដាក់ដោយ លោក ខៀវ សំផន ដែលឯកសារនោះមាន៧ ទំព័រ។

ថ្ងៃ ហើយស្នើសុំរយៈពេលបន្ថែមសម្រាប់ដាក់បណ្តឹងនេះជាភាសាខ្មែរ ដោយរាប់បញ្ចូលទាំងរយៈពេលដែលប្រើប្រាស់សម្រាប់ធ្វើការបកប្រែបណ្តឹងនេះផងដែរ។

## ហេតុដូច្នេះ

១៨. លោក ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ពន្លាត** ចំនួនទំព័រអតិបរមានៃបណ្តឹងពាក់ព័ន្ធនឹងករណីអញ្ញត្រកម្មបឋម
- **ពន្យារថេរវេលា** ក្នុងការដាក់បណ្តឹងពាក់ព័ន្ធនឹងករណីអញ្ញត្រកម្មបឋមដែលបានបកប្រែជាភាសាខ្មែរ។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី ស សុវាន | ភ្នំពេញ | [signature] |
| P | មេធាវី Jacques VERGÈS | ប៉ារីស | [signature] |
| P | មេធាវី Philippe GRECIANO | ប៉ារីស | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |